លេខ ៣២ ចេញផ្សាយថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែមករា ឆ្នាំ២០២៤


TRUST REGULATOR

និយ័តករបរធនបាលកិច្ច

គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ

បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា


## កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣

នាព្រឹកថ្ងៃអង្គារ ១៣រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោក ឃុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។

## មាតិកា


- កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣ ទំព័រទី១
- សិក្ខាសាលាផ្សព្វផ្សាយស្ដីពី កាតព្វកិច្ចផ្ដល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល ទំព័រទី២
- សិក្ខាសាលាផ្សព្វផ្សាយស្ដីពី ការទទួលស្គាល់ក្រុមហ៊ុនផ្ដល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ទំព័រទី២
- កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទំព័រទី៣
- កិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមការងារនៃក្រុមហ៊ុន PwC ទំព័រទី៣
- កិច្ចការងារសង្គមនៅមជ្ឈមណ្ឌលទារក និងកុមារជាតិ ទំព័រទី៤
- កម្មវិធីបញ្ជ្រាបការយល់ដឹងស្ដីពី នីតិវិធីអនុវត្តការងារសម្រាប់គ្រប់មុខសញ្ញាកិច្ចលទ្ធកម្មសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ទំព័រទី៤
- កិច្ចប្រជុំកម្រិតអន្តរនាយកដ្ឋានដើម្បីពិនិត្យលើខ្លឹមសារសេចក្ដីព្រាងរបាយការណ៍សមិទ្ធផលការងារប្រចាំឆ្នាំ២០២១-២២ របស់និយ័តករបរធនបាលកិច្ច ទំព័រទី៥
- សិក្ខាសាលាស្ដីពី កាលានុវត្តភាពអាជីវកម្មដែលកំពុងរីកចម្រើន÷ ការអភិវឌ្ឍន៍នៃវិស័យបរធនបាលកិច្ចនៅកម្ពុជា ទំព័រទី៥
- សិក្ខាសាលាស្ដីពី ការវាយតម្លៃហានិភ័យថ្នាក់ជាតិស្ដីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លើកទី២ (NRA II) សម្រាប់ម៉ូឌុល៧ និងម៉ូឌុល១៣ ទំព័រទី៥
- កិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្ដីពី ការអនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២៤ ទំព័រទី៦
- វគ្គបណ្ដុះបណ្ដាលនិងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៤ ទំព័រទី៦
- កិច្ចប្រជុំក្រុមការងារសម្របសម្រួលការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់ពន្ធដារក្នុងវិស័យបរធនបាលកិច្ច ទំព័រទី៧
- សិក្ខាសាលាស្ដីពី ការស៊ើបអង្កេតហិរញ្ញវត្ថុស្របគ្នា (Parallel Financial Investigations) ទំព័រទី៧
- កិច្ចពិភាក្សា÷ បទពិសោធអនុវត្ត បញ្ហាប្រឈម និងកាលានុវត្តភាពនៃវិស័យបរធនបាលកិច្ចនៅកម្ពុជា ទំព័រទី៨
- កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ២០២៤ ទំព័រទី៨




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី កាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល

នាព្រឹកថ្ងៃអង្គារ ១៣រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីការដាក់ឱ្យអនុវត្តប្រកាសស្តីពី "កាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយដល់សាធារណជន ជាពិសេសបរធនបាលដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.** អំពីការអនុវត្តនូវកាតព្វកិច្ចផ្តល់របាយការណ៍ ការជូនដំណឹង និងការស្នើសុំការអនុញ្ញាតរបស់បរធនបាលដែលធ្វើប្រតិបត្តិការបរធនបាលកិច្ច នៅក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងដើម្បីធានាឱ្យបាននូវការបំពេញកាតព្វកិច្ច និងការធ្វើប្រតិបត្តិការបរធនបាលកិច្ចរបស់បរធនបាលប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដោយអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ សិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ព្រមទាំងថ្នាក់ដឹកនាំ និងតំណាងក្រុមហ៊ុនបរធនបាល, ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬរក្សាទុក និងបរធនបាលរូបវន្តបុគ្គលឯករាជ្យដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.**។



រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល"។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច

ព្រឹកថ្ងៃអង្គារ ៦កើត ខែបុស្ស ឆ្នាំថោះ ចត្វាស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីការដាក់ឱ្យអនុវត្តប្រកាសស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច" នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** ។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយអំពីលក្ខខណ្ឌ និងនីតិវិធីនៃការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចធ្វើអាជីវកម្មរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ដល់សាធារណជន, បរធនបាល និងបុគ្គលពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ជាពិសេសក្រុមហ៊ុនផ្តល់សេវាសវនកម្ម ដែលកំពុងធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបំណងដាក់ពាក្យស្នើសុំការទទួលស្គាល់ពី **ន.ប.ធ.** ក្នុងការផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ដើម្បីធានាឱ្យបាននូវគុណភាពសវនកម្ម និងអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យបរធនបាលកិច្ច។

សិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ព្រមទាំងថ្នាក់ដឹកនាំ និងតំណាងក្រុមហ៊ុនបរធនបាល, ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬរក្សាទុកនិងបរធនបាលរូបវន្តបុគ្គលឯករាជ្យដែលទទួលបាន



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

អាជ្ញាបណ្ណ/ ការអនុញ្ញាតពី **ន.ប.ធ.** ព្រមទាំងក្រុមហ៊ុនផ្តល់សេវាសវនកម្ម។



រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច"។

## កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នាព្រឹកថ្ងៃពុធ ៧កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ និងឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## កិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមការងារនៃក្រុមហ៊ុន PwC

នារសៀលថ្ងៃពុធ ៧កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ ឯកឧត្តមអគ្គនាយករង លោក-កញ្ញាប្រធាននាយកដ្ឋាន ប្រធានស្តីទីនាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញ បានទទួលជួបប្រជុំពិភាក្សាការងារជាមួយក្រុមការងារនៃក្រុមហ៊ុន PwC តំណាងដោយ **លោក នៅ រ៉េមី**, Associate Partner, **លោកស្រី កែវ កល្យាណ**, Manager និង**លោក ឡាញ់ ពិទូរ្យ**, Senior Consultant ដែលទទួលបន្ទុកជាអ្នកពិគ្រោះយោបល់លើការរៀបចំសេចក្តីព្រាងបច្ចុប្បន្នភាពយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (២០២១-២០៣០) ដើម្បីផ្តល់នូវព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច សម្រាប់ផ្តល់ជាធាតុចូលទៅក្នុងសេចក្តីព្រាងបច្ចុប្បន្នភាពយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (២០២១-២០៣០)។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ កិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមការងារនៃក្រុមហ៊ុន PwC។

## កិច្ចការងារសង្គមនៅមជ្ឈមណ្ឌលទារក និងកុមារជាតិ

នាព្រឹកថ្ងៃសុក្រ ៩កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) រួមដំណើរដោយឯកឧត្តមអគ្គនាយករង លោក លោកស្រីជាថ្នាក់ដឹកនាំបច្ចេកទេស និងសហការីនៃ **ន.ប.ធ.** បាននាំយកអំណោយជាសម្ភារៈប្រើប្រាស់ និងគ្រឿងឧបភោគបរិភោគ ព្រមទាំងរៀបចំជាអាហារសាមគ្គី ជូនដល់មជ្ឈមណ្ឌលទារក និងកុមារជាតិ ដែលជាមជ្ឈមណ្ឌលផ្តល់ការមើលថែទាំក្មេងៗ ដែលកំព្រា គ្មានអាណាព្យាបាល និងមានពិការភាព ទាំងការរស់នៅ ហូបចុក និងការមើលថែទាំជំងឺផ្សេងៗ។

កម្មវិធីនេះក៏មានការចូលរួមពីតំណាងក្រុមបរធនបាលពាក់ព័ន្ធផងដែរ។



រូបភាព៖ កិច្ចការងារនៅសង្គមមជ្ឈមណ្ឌលទារក និងកុមារជាតិ។

## កម្មវិធីបញ្ជ្រាបការយល់ដឹងស្តីពី នីតិវិធីអនុវត្តការងារសម្រាប់គ្រប់មុខសញ្ញាកិច្ចលទ្ធកម្មសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)

នាព្រឹកថ្ងៃចន្ទ ១២កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តម សុខ ដារ៉ា អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ឃុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ អមដោយសហការី បានចូលរួមកម្មវិធីបញ្ជ្រាបការយល់ដឹងស្តីពី "នីតិវិធីអនុវត្តការងារសម្រាប់គ្រប់មុខសញ្ញាកិច្ចលទ្ធកម្មសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កម្មវិធីបញ្ជ្រាបការយល់ដឹងស្តីពី "នីតិវិធីអនុវត្តការងារសម្រាប់គ្រប់មុខសញ្ញាកិច្ចលទ្ធកម្មសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំកម្រិតអន្តរនាយកដ្ឋានដើម្បីពិនិត្យលើខ្លឹមសារសេចក្តីព្រាងរបាយការណ៍សមិទ្ធផលការងារប្រចាំឆ្នាំ ២០២១-២២ របស់និយ័តករបរធនបាលកិច្ច

នាព្រឹកថ្ងៃអង្គារ ១៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំកម្រិតអន្តរនាយកដ្ឋានដើម្បីពិនិត្យលើខ្លឹមសារសេចក្តីព្រាងរបាយការណ៍សមិទ្ធផលការងារប្រចាំឆ្នាំ២០២១-២២ របស់និយ័តករបរធនបាលកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីលោក-កញ្ញា ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងមន្ត្រីជំនាញនៃ **ន.ប.ធ.**។




**រូបភាព៖** កិច្ចប្រជុំកម្រិតអន្តរនាយកដ្ឋានដើម្បីពិនិត្យលើខ្លឹមសារសេចក្តីព្រាងរបាយការណ៍សមិទ្ធផលការងារប្រចាំឆ្នាំ២០២១-២២ របស់និយ័តករបរធនបាលកិច្ច។

## សិក្ខាសាលាស្តីពី កាលានុវត្តភាពអាជីវកម្មដែលកំពុងរីកចម្រើន៖ ការអភិវឌ្ឍន៍នៃវិស័យបរធនបាលកិច្ចនៅកម្ពុជា

ថ្ងៃពុធ ១៤ កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានផ្តល់កិត្តិយសចូលរួមជាអធិបតីដើម្បីថ្លែងសុន្ទរកថាគន្លឹះ និងជាវាគ្មិនកិត្តិយស ក្នុងសិក្ខាសាលាស្តីពី "កាលានុវត្តភាពអាជីវកម្មដែលកំពុងរីកចម្រើន៖ ការអភិវឌ្ឍន៍នៃវិស័យបរធនបាលកិច្ចនៅកម្ពុជា" ដែលរៀបចំដោយសភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា (AmCham) នៅសណ្ឋាគារហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ។

សិក្ខាសាលានេះមានគោលបំណងដើម្បីប្រមូលផ្តុំអ្នកជំនាញ និងតួអង្គពាក់ព័ន្ធក្នុងទីផ្សារបរធនបាលកិច្ច ដើម្បីលើកកម្ពស់ការយល់ដឹងពីសារៈសំខាន់ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច ដែលជាយន្តការសម្រាប់ការគ្រប់គ្រង ចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិ ប្រកបដោយទំនុកចិត្ត។




**រូបភាព៖** សិក្ខាសាលាស្តីពី "កាលានុវត្តភាពអាជីវកម្មដែលកំពុងរីកចម្រើន៖ ការអភិវឌ្ឍន៍នៃវិស័យបរធនបាលកិច្ចនៅកម្ពុជា"។

## សិក្ខាសាលាស្តីពី ការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លើកទី២ (NRA II) សម្រាប់ម៉ូឌុល៧ និងម៉ូឌុល១៣

នាថ្ងៃពុធ ១៤កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **កញ្ញា ឈាន សុខាវី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច អមដោយសហការី បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ដោយផ្ទាល់ (Physical Consultative Workshop) ស្តីពី "ការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លើកទី២ (NRA II) សម្រាប់ម៉ូឌុល៧ និងម៉ូឌុល១៣" ក្រោមការរៀបចំដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (CAFIU) ជាមួយធនាគារពិភពលោក ដោយមានការចូលរួមពីតំណាង ក្រសួងមហាផ្ទៃ, ក្រសួងពាណិជ្ជកម្ម, ក្រសួងយុត្តិធម៌, ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ធនាគារជាតិនៃកម្ពុជា, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, អគ្គស្នងការដ្ឋាននគរបាលជាតិ, គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា, គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, និងនិយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារសរុបចំនួន ៣០ រូប។




**រូបភាព៖** សិក្ខាសាលាស្តីពី "ការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លើកទី២ (NRA II) សម្រាប់មុំខុលទី៧ និងម៉ូឌុល១៣"។

## កិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្តីពី ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២៤

នាព្រឹកថ្ងៃសុក្រ ១រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.**,**លោក ឃុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ អមដោយសហការី បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្តីពី "ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២៤" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



**រូបភាព៖** កិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្តីពី ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២៤។

## វគ្គបណ្តុះបណ្តាលនិងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៤

នាព្រឹកថ្ងៃចន្ទ ៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញប្រកាសបើក "វគ្គបណ្តុះបណ្តាលនិងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៤" ដែលរៀបចំដោយនិយ័តករបរធនបាលកិច្ចនៅ អគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៤ នេះ ត្រូវបានរៀបចំរយៈពេលចំនួន ៣ ថ្ងៃពេញ ចាប់ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ និងមានអ្នកចូលរួមសរុបចំនួន ១៦២ រូប ដែលមានសមាសភាពចូលរួមពីក្រុមហ៊ុននិងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធន-បាលកិច្ច,បុគ្គលដែលមានបំណងផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច និងសាធារណជន។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាព៖ "វគ្គបណ្ដុះបណ្ដាលនិងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៤"។

## កិច្ចប្រជុំក្រុមការងារសម្របសម្រួលការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់ពន្ធដារក្នុងវិស័យបរធនបាលកិច្ច

នារសៀលថ្ងៃចន្ទ ៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាអនុប្រធានក្រុមការងារសម្របសម្រួលការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់ពន្ធដារក្នុងវិស័យបរធនបាលកិច្ច អមដោយ **ឯកឧត្តម នាង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំសហការី ចូលរួមកិច្ចប្រជុំក្រុមការងារសម្របសម្រួលការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់ពន្ធដារក្នុងវិស័យបរធនបាលកិច្ច តាមប្រព័ន្ធអនឡាញ (Zoom) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារសម្របសម្រួលការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់ពន្ធពន្ធដារក្នុងវិស័យបរធនបាលកិច្ច ដើម្បីពិនិត្យ និងពិភាក្សាលើកិច្ចការងារពាក់ព័ន្ធនឹងការកំណត់វិធាន និងបែបទពន្ធដារក្នុងវិស័យបរធនបាលកិច្ច។




រូបភាព៖ កិច្ចប្រជុំក្រុមការងារសម្របសម្រួលការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់ពន្ធដារក្នុងវិស័យបរធនបាលកិច្ច។

## សិក្ខាសាលាស្តីពី ការស៊ើបអង្កេតហិរញ្ញវត្ថុស្របគ្នា (Parallel Financial Investigations)

នាថ្ងៃអង្គារ ៥រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**), **កញ្ញា ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច អមដោយសហការី បានចូលរួមសិក្ខា-សាលាស្តីពី "ការស៊ើបអង្កេតហិរញ្ញវត្ថុស្របគ្នា (Parallel Financial Investigations)" ក្រោមការរៀបចំដោយក្រុមការងារហិរញ្ញវត្ថុ (Financial Action Task Force-FATF) វេលាម៉ោង ២:00 នាទីរសៀល ម៉ោងនៅក្នុងទីក្រុងប៉ារីស ប្រទេសបារាំង ត្រូវនឹងម៉ោង ៨:00 នាទីយប់ ម៉ោងនៅភ្នំពេញ តាមប្រព័ន្ធអនឡាញ (Webinar) ដោយមានការចូលរួមពីសមាជិកនៃ **ក.ប.ស.ហ.**, ចៅក្រម, ព្រះរាជអាជ្ញា និងតំណាងមកពីនិយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។



រូបភាព៖ សិក្ខាសាលាស្តីពី ការស៊ើបអង្កេតហិរញ្ញវត្ថុស្របគ្នា (Parallel Financial Investigations)។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចពិភាក្សា៖ បទពិសោធអនុវត្ត បញ្ហាប្រឈម និង កាលានុវត្តភាពនៃវិស័យបរធនបាលកិច្ចនៅកម្ពុជា

កាលពីព្រឹកថ្ងៃពុធ ៦ រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមធ្វើជាវាគ្មិនកិត្តិយសក្នុងកម្មវិធីកិច្ចពិភាក្សា៖ បទពិសោធអនុវត្ត បញ្ហាប្រឈម និងកាលានុវត្តភាពនៃវិស័យបរធនបាលកិច្ចនៅកម្ពុជា នៃកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៤ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច ជាន់ទី១៥។

កិច្ចពិភាក្សានេះ មានការអញ្ជើញចូលរួមដោយវាគ្មិនកិត្តិយសដែល សុទ្ធសឹងជាអ្នកជំនាញក្នុងវិស័យបរធនបាលកិច្ច, វិស័យធុរកិច្ច និងវិស័យច្បាប់ រួមមាន៖ **លោកស្រី សុខ វណ្ណសិកា** នាយកប្រតិបត្តិនៃការិយាល័យមេធាវី សិដ្ឋាល័យ ជាអ្នកសម្របសម្រួលក្នុងកិច្ចពិភាក្សា, **ឯកឧត្តមបណ្ឌិត តាន់ មុនីវណ្ណ** ប្រធានសហព័ន្ធឧស្សាហកម្មយានយន្តនៅកម្ពុជា, **ឧកញ៉ា សុខ ពិសិដ្ឋ** ប្រធានសហព័ន្ធនិយោជក និងសមាគមសភាពាណិជ្ជកម្មកម្ពុជា, **ឯកឧត្តម លី តៃសេង** នាយកប្រតិបត្តិនៃក្រុមហ៊ុនមេធាវី HBS, និង**លោក គុយ លីម** ប្រធានក្រុមហ៊ុនប្រាយវ៉េតផ័រហោវខូភើស៍ (ខេមបូឌា)។

នៅក្នុងកិច្ចពិភាក្សានេះ វាគ្មិនកិត្តិយស បានធ្វើការចែករំលែកអំពីបទពិសោធន៍ក្នុងការគ្រប់គ្រង និងចាត់ចែងបរធនបាលកិច្ច អត្ថប្រយោជន៍នៃការបង្កើតវិស័យបរធនបាលកិច្ច និងបញ្ហាប្រឈមដែលធ្លាប់បានជួបប្រទះក្នុងការអនុវត្តការងារកន្លងមក ព្រមទាំងបានចែករំលែកអំពីទស្សនវិស័យអំពីវិស័យបរធនបាលកិច្ចផងដែរ។




**រូបភាព៖** កិច្ចពិភាក្សា៖ បទពិសោធអនុវត្ត បញ្ហាប្រឈម និងកាលានុវត្តភាពនៃវិស័យបរធនបាលកិច្ចនៅកម្ពុជា។

## កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ២០២៤

នាព្រឹកថ្ងៃពុធ ៦រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** បានដឹកនាំថ្នាក់ដំនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ព្រមទាំងតំណាងក្រុមហ៊ុនបរធនបាល បរធនបាលរូបវន្តបុគ្គលឯករាជ្យ ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាពឬរក្សាទុកក្នុងវិស័យបរធនបាលកិច្ចអញ្ជើញចូលរួមក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ "កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ២០២៤" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ ឆ្នេរសុខា ខេត្តព្រះសីហនុ។




**រូបភាព៖** កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ២០២៤។